# របៀបបោះឆ្នោតក្នុងការបោះឆ្នោតរដ្ឋ

ខ្មែរ
Khmer

ការបោះឆ្នោតគឺជាឱកាសរបស់អ្នកក្នុងការបញ្ចេញមតិ ថាតើអ្នកណាតំណាងឱ្យអ្នកនៅក្នុងរដ្ឋាភិបាល។

ការបោះឆ្នោតរបស់អ្នកគឺជាជម្រើសរបស់អ្នក។ អ្នកជ្រើសរើសនរណាដែលត្រូវបោះឆ្នោតឱ្យ។

ការបោះឆ្នោតរបស់អ្នកគឺសម្ងាត់។ គ្មាននរណាផ្សេងទៀតមើលឃើញថាអ្នកបោះឆ្នោតឱ្យអ្នកណាទេ។

## របៀបបោះឆ្នោតក្នុងការបោះឆ្នោតរដ្ឋ

- អ្នកអាចស្នើសុំជំនួយបានគ្រប់ពេល។
- អ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មី ប្រសិនបើអ្នកធ្វើខុស។
- សួរបុគ្គលិករៀបចំការបោះឆ្នោត ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់។

### 1

**នៅកន្លែងបោះឆ្នោត អ្នកនឹងត្រូវបានគេសួរសំណួរ 3៖**

- តើអ្នកបានបោះឆ្នោតនេះរួចហើយឬនៅ?
- តើឈ្មោះពេញរបស់អ្នកគឺជាអ្វី?
- តើអាសយដ្ឋានដែលអ្នករស់នៅគឺជាអ្វី?



### 2

**អ្នកនឹងទទួលបានសន្លឹកឆ្នោត 2 សន្លឹក៖**

- **សន្លឹកឆ្នោតតូច** - សម្រាប់សភាតំណាងរាស្ត្រ (Legislative Assembly) (សភាជាន់ទាប)
- **សន្លឹកឆ្នោតធំ** - សម្រាប់ក្រុមប្រឹក្សានីតិបញ្ញត្តិ (Legislative Council) (សភាជាន់ខ្ពស់)



### 3

**យកសន្លឹកឆ្នោតរបស់អ្នកទៅកាន់កន្លែងបោះឆ្នោតរបាំងក្រដាសរឹង**



WESTERN AUSTRALIAN
Electoral Commission

More information
elections.wa.gov.au

General Enquiries Line
13 63 06 or (08) 9214 0400

4

## បំពេញសន្លឹកឆ្នោតរបស់អ្នក៖

### សន្លឹកឆ្នោតតូច (សភាតំណាងរាស្ត្រ ) (Legislative Assembly)

ដាក់លេខក្នុងគ្រប់ប្រអប់ការ៉េ ទៅតាមលំដាប់នៃជម្រើសរបស់អ្នក។

ឧទាហរណ៍ សរសេរលេខ ១ សម្រាប់ជម្រើសទីមួយរបស់អ្នក, លេខ ២ សម្រាប់ជម្រើសទីពីររបស់អ្នក ហើយបន្តរហូតដល់អ្នកបានដាក់លេខក្នុងប្រអប់ការ៉េទាំងអស់។

- កុំទុកប្រអប់ការ៉េឱ្យនៅទទេ។
- កុំប្រើសញ្ញាធីក ឬសញ្ញាខ្វែង។ ប្រើតែលេខប៉ុណ្ណោះ។
- កុំប្រើលេខដដែល។




### សន្លឹកឆ្នោតធំ (ក្រុមប្រឹក្សានីតិបញ្ញត្តិ) (Legislative Council)

អ្នកអាចជ្រើសរើសថាតើអ្នកចង់បោះឆ្នោត ‘ខាងលើ’ ឬ ‘ខាងក្រោម’ ខ្សែបន្ទាត់ក្រាស់នៅលើសន្លឹកឆ្នោត។ អ្នកមិនអាចធ្វើទាំងពីរបានទេ។

គូសសន្លឹកឆ្នោត៖

**ខាងលើខ្សែបន្ទាត់៖**
ដាក់លេខក្នុងប្រអប់ការ៉េលេខមួយ ឬច្រើន។

**ខាងក្រោមខ្សែបន្ទាត់៖**
ដាក់លេខក្នុងប្រអប់ការ៉េ ២០ ឬច្រើន ទៅតាមលំដាប់នៃជម្រើសរបស់អ្នក។ អ្នកមិនចាំបាច់ដាក់លេខក្នុងប្រអប់ការ៉េទាំងអស់ទេ ប្រសិនបើអ្នកមិនចង់។




5

## ដាក់សន្លឹកឆ្នោតរបស់អ្នកនៅក្នុងប្រអប់សន្លឹកឆ្នោតទាំង 2

- សន្លឹកឆ្នោតតូច - ប្រអប់សភាតំណាងរាស្ត្រ (Legislative Assembly)
- សន្លឹកឆ្នោតធំ - ប្រអប់ក្រុមប្រឹក្សានីតិបញ្ញត្តិ (Legislative Council)



Interpreter

**If you need an interpreter, please call TIS National on 131 450 and ask them to call the WA Electoral Commission on (08) 9214 0400.**

Our business hours are from **8:30 am to 4:30 pm.**

WESTERN AUSTRALIAN Electoral Commission

More information
**elections.wa.gov.au**

General Enquiries Line
**13 63 06** or **(08) 9214 0400**